


និពន្ធដោយ TukTuk

រូបភាពដោយ Hen Choven



រតនានិងមករាជាបងប្អូននឹងគ្នា។

ថ្ងៃមួយ កុមារទាំងពីរកំពុងលេងជាមួយមិត្តភក្តិនៅក្បែរផ្ទះដូចសព្វមួយដង។



រតនាសួរ « ហ្អេ! តើពួកឯងធ្លាប់ឃើញយក្សចម្លែកទេ? »
មករាឆ្លើយ « ខ្ញុំមិនដែលឃើញទេ បងប្រាប់ខ្ញុំផងមើល! »



រតនាតបវិញ « គាត់បើករ៉ឺម៉កកង់បី ហើយគ្រប់គ្នាហៅគាត់ថា យក្ស »។
មករាសួរទៀត « មាឌគាត់ធំទេ? »





រតនាឆ្លើយ « បងឮគេថាមាឌគាត់ធំ ហើយខ្ពស់ប៉ុន
ដើមត្នោតហ្ន៎ ហើយស្បែកជើងគាត់ធំប៉ុនទូក... »



ហើយគាត់ចូលចិត្តញុំាក្មេងៗជាអាហារ។

មករាភ្លាត់មាត់ « អ្នំា ញុំាក្មេងៗ! ខ្ញុំមិនចង់ជួបគាត់ទេ »។



ថ្ងៃមួយ រតនានិងមករាបានបែកកង់ពេលកំពុងជិះតាមផ្លូវពីសាលារៀនត្រឡប់ទៅផ្ទះវិញ។



រតនានិងមករាមិនដឹងធ្វើយ៉ាងម៉េច ក៏អង្គុយចាំនៅតាមផ្លូវក្បែរមាត់ទឹក
រង់ចាំក្រែងលោមាននរណាម្នាក់ជិះកាត់ ដើម្បីសុំដោយសារ។



មិនយូរប៉ុន្មាន រ៉ឺម៉កកង់បីមួយបានបើកមកដល់។ កុមារទាំងពីរបក់ដៃឃាត់រ៉ឺម៉កកង់បី។



រ៉ឺម៉កកង់បីនោះមានពណ៌ខៀវ ហើយអ្នកបើកក៏ពាក់មួកការពារសុវត្ថិភាពពណ៌ខៀវដែរ។



នៅបាំងខាងក្រោយមានសត្វអ្វីម្យ៉ាងដែលកុមារទាំងពីរមិនដែលស្គាល់។



តេនានិងមករាមានអារម្មណ៍ភ័យតិចៗ។



ពេលដែលគាត់ចុះពីលើរ៉ឺម៉កកង់បី គាត់ឈរខ្ពស់ឡើងជង្គ្រោង។
រតនានិងមករាកាន់តែភ័យថែមទៀត។



អ្នកបើករ៉ឺម៉កកង់បីដោះមួកការពារសុវត្ថិភាពចេញ...



អ្នកបើករុឺម៉កកង់បីដោះមួកការពារសុវត្ថិភាពចេញ...



...គាត់មានមុខចម្លែកខ្លាំងណាស់!
រតនានិងមករាភិតភ័យកាន់តែខ្លាំង។



អ្នកបើកម៉ូតូកង់បីនិយាយទាំងសម្លេងធំៗ « សួស្ដី! ខ្ញុំឈ្មោះយ៉េក! មានអ្វីឱ្យខ្ញុំជួយទេ? »



រតនានិងមករាងើយមុខមើលទៅយ៉េក ហើយខ្សឹបគ្នា « តើគាត់និយាយថាគាត់ឈ្មោះយក្សមែនទេ? ភ្នឺយ! ខ្ញុំគិតថាយើងគួរតែរត់ទៅល្អជាង »។



យ៉េក ឮអ្វីដែលក្មេងៗខ្សឹបគ្នា។

គាត់តប « កុំបារម្ភអីណាក្មេងៗ! ខ្ញុំមិនមែនជា យក្សទេ!



ខ្ញុំឈ្មោះយ៉េកទេតើ »។ រតនានិងមករានៅតែភ័យខ្លាចដដែល។



អ្នកដែលអង្គុយនៅបាំងខាងក្រោយរុឺម៉កកង់បីក៏ចុះមក
« សួស្តី! ខ្ញុំឈ្មោះខេទី! ខ្ញុំគឺជាសត្វ ខូអាឡា! តើអ្នកទាំងពីរឈ្មោះអ្វីដែរ? »



រតនាតបវិញ « ខ្ញុំមិនអាចប្រាប់ឈ្មោះរបស់ខ្ញុំទៅអ្នកបានទេ
ព្រោះថា អ្នកគឺជាមនុស្សចម្លែក... »



រតនានិងមករាកាន់តែភ័យខ្លាំងឡើងៗ។



កុមារទាំងពីរមិនដឹងធ្វើយ៉ាងម៉េច ដើម្បីរត់គេចឱ្យឆ្ងាយពីមនុស្សចម្លែកទាំងពីរនាក់នោះទេ។



« ຕືບໆ! ຕືບໆ! »




ពួកគេបានឮសំឡេងស៊ីប្លេម៉ូតូ ហើយបុរសម្នាក់ក៏បន្លឺសំឡេងឡើង

« សួស្តី យ៉េក! សួស្តី ខេទី! សួស្តីក្មេងៗ! ទាំងអស់គ្នាសុខសប្បាយជាទេ? »



មករា ងាកទៅទាំងភ្ញាក់ផ្អើល « អូ! លោកគ្រូតើ! ជម្រាបសួរលោកគ្រូ
តើលោកគ្រូស្គាល់យ៉េកនិងខេទីដែរមែនទេ? »



លោកគ្រូសុខឆ្លើយ « បាទស្គាល់!ពួកយើងគឺជាមិត្តភក្តិនឹងគ្នាទៀតផង »។



លោកគ្រូសុខសួរមករានិងរតនា « តើអ្នកទាំងពីរនាក់កំពុងធ្វើអ្វីហ្នឹង? »



រតនាឆ្លើយ « ចាសលោកគ្រូ កង់របស់ខ្ញុំបានបែក ហើយពួកខ្ញុំកំពុងរង់ចាំក្រែងមាន
អ្នកណាម្នាក់មកជួយពួកខ្ញុំហ្នឹងណា ហើយយ៉េកនិងខេទីក៏បានមកដល់ »។



មករាលួចសួរលោកគ្រូសុខខ្សឹបៗ « លោកគ្រូៗ! តើយ៉េកចូលចិត្តញ៉ាំក្មេងៗ
ជាអាហារមែនទេ?»



លោកគ្រូសុខឆ្លើយទាំងអស់សំណើច « អត់ទេ!អត់ទេ!វាមិនមែនជាការពិតនោះទេ »។



យ៉េកឮដូចនេះ ក៏និយាយថា « កុំយល់ច្រឡំនឹងខ្ញុំអី! ខ្ញុំមិនចូលចិត្តញ៉ាំក្មេងៗទេ តែខ្ញុំចូលចិត្តញ៉ាំភីហ្សានិងផ្លែឪឡឹក »។ ទាំងអស់គ្នាសើចគឹល... « ហាសហា ហិហិ »។



យ៉េកសួររតនានិងមករា « តើអ្នកទាំងពីរឈ្មោះអ្វីដែរ? »

កុមារទាំងពីរឆ្លើយបន្តបន្ទាប់គ្នា « ខ្ញុំឈ្មោះ រតនា ចំណែកខ្ញុំឈ្មោះ មករា »។



យ៉េកបន្ត « អូ! រីករាយណាស់ដែលបានស្គាល់ រតនានិងមករា!
ចាំខ្ញុំជូនអ្នកទាំងពីរទៅផ្ទះណ៎ា! »



ទាំងអស់គ្នាក៏ជម្រាបលាលោកគ្រូសុខ។ យ៉េកបានចងកង់របស់រតនានិងមករា នៅពីក្រោយរ៉ឺម៉កកង់បី។



បន្ទាប់មក កុមារទាំងពីរក៏ឡើងលើរ៉ឺម៉កកង់បី ហើយយ៉េក ក៏បើកវាចេញទៅ។
រតនានិងមករាជដែកលេងជាមួយ ខេទីតាមផ្លូវរហូតដល់ផ្ទះ។



ខេទីបាននិយាយប្រាប់កុមារទាំងពីរអំពីប្រទេស អូស្ត្រាលីដែលជាទីកន្លែងកំណើតរបស់គាត់និងយ៉េក។



រតនានិងមករាមានសំណួរជាច្រើនដែលចង់សួរទៅកាន់គាត់ ប៉ុន្តែពេលវេលាខ្លីពេក
រ៉ឺម៉កកង់បីក៏បានទៅដល់ផ្ទះរបស់ពួកគេ។



រតនានិងមករាលោតចុះពីលើរ៉ឺម៉កកង់បី « អរគុណច្រើន យ៉េកនិងខេទី! ថ្ងៃក្រោយជួបគ្នា! »



ហើយរតនានិងមករាក៏រត់ទៅលេងជាមួយមិត្តភក្តិរបស់ពួកគេបាត់ទៅ។



រតនាបានប្រាប់មិត្តភក្តិរបស់ពួកគេ « ពួកខ្ញុំបានជួបយក្សចម្លែកនោះហើយ មាឌគាត់ធំ
ហើយខ្ពស់មែន



តែមិនមែនខ្ពស់ដូចជាដើមត្នោតនោះទេ ស្បែកជើងគាត់ក៏ធំដែរ
តែមិនមែនធំប៉ុនទូកនោះទេ ហើយគាត់ក៏មិនមែនញ៉ាំក្មេងៗជាអាហារដែរ



តែគាត់ចូលចិត្តញ៉ាំភីហ្សានិងផ្លែឪឡឹកតែប៉ុណ្ណោះ គាត់ឈ្មោះថា យ៉េក
មិនមែនឈ្មោះថា យក្សនោះទេ



មិត្តភក្តិរបស់គាត់ឈ្មោះ ខេទី គឺជាសត្វ ខូអាឡា ហើយពួកគេក៏ជាមិត្តភក្តិ
របស់លោកគ្រូសុខផងដែរ »។



មករាបន្តទៀត « ខ្ញុំចង់ជួបពួកគាត់ម្តងទៀតក្នុងពេលឆាប់ៗនេះ »។



ក្មេងៗទាំងអស់ក៏បន្ទរ « មែនហើយៗ! សូម្បីតែពួកយើងក៏ចង់ជួបពួកគាត់ដែរ »។



ចប់ដោយបរិបូរណ៍

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

អង្គការរ៉ឺម៉កកង់បីសម្រាប់កុមារ(R4C)គឺជាអង្គការដែល មិនរកប្រាក់ចំណេញ និងផ្តោតលើការអប់រំកុមារតូច ក្នុងប្រទេសកម្ពុជា។

អង្គការR4Cកំពុងដំណើរការគម្រោងកម្មវិធីបណ្ណាល័យចល័តតាមប្រព័ន្ធអនឡាញ ដែលមាននិន្នាការទៅលើសាលាមត្តេយ្យរដ្ឋ និងមត្តេយ្យសហគមន៍។

អង្គការR4Cបានចូលរួមអភិវឌ្ឍន៍ធនធានដ៏សមស្រប ទៅនឹងកម្មវិធីសិក្សារបស់ក្រសួង និងមានវគ្គបំប៉ន លោកគ្រូ អ្នកគ្រូ។
សូមចូលទៅកាន់គេហទំព័រដើម្បីទទួលបានធនធានបង្រៀន៖ https://rermork.org/

ទទួលបានព័ត៌មានបន្ថែម

TUKTUK

Rotary

មូលនិធិផ្តល់ដោយអង្គការTukTuk និងអង្គការរ៉ូតារីក្លឹប។

សៀវភៅរឿងនេះគឺនិពន្ធដោយ **Robert McCurdy** និង**Roberta Dahl** ជាអ្នកស្ម័គ្រចិត្តដោយក្តីមេត្តាធម៌។ ពួកយើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អ្នកស្ម័គ្រចិត្ត និងបុគ្គលិកទាំងអស់នៅក្នុងអង្គការជាមួយនឹង **Sally Heinrich** ដែលបានចូលរួមកែសម្រួល និងបកប្រែសៀវភៅរឿងនេះ។

ទទួលបានគំនូរជីវចល

ទទួលបានធនធានបង្រៀន